

# សន្និបាត

# បូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការឆ្នាំ២០២៤

# របស់ក្រសួងផែនការ

ថ្ងៃចន្ទ ១៥រោច ខែផល្គុន-ថ្ងៃអង្គារ ១កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ថ្ងៃទី០៨-០៩ ខែមេសា ឆ្នាំ២០២៤

បទបង្ហាញ៖ ស្តីពីបូកលទ្ធផលការងារសំខាន់ៗ និងទិសដៅការងារឆ្នាំ២០២៤

របស់មន្ទីរផែនការរាជធានី ខេត្ត

# មាតិកា

១.បេសកម្ម និងតួនាទីភារកិច្ចមន្ទីរផែនការខេត្ត

២.លទ្ធផលសកម្មភាពការងារឆ្នាំ២០២៣

៣.បញ្ហាប្រឈម និងសំណូមពរ

៤. ផែនការសកម្មភាពការងារសំខាន់ៗសម្រាប់ឆ្នាំ២០២៤

# ១.បេសកកម្ម និងតួនាទីភារកិច្ចរបស់មន្ទីរផែនការ

**បេសកកម្ម តួនាទីភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង** របស់មន្ទីរផែនការរាជធានី ខេត្ត មានក្នុងខ្លឹមសារប្រកាស លេខ០០១២ផក.ប្រក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងផែនការស្តីពីការរៀបចំនិងការប្រព្រឹត្តិ ទៅរបស់មន្ទីរផែនការរាជធានី-ខេត្ត។

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួង ផែនការ**
លេខ: ០០១២ ផក

**ប្រកាស**
**ស្តីពី**
**ការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរផែនការរាជធានី ខេត្ត**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦៤ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង

១/១៣

ប្រការ ៦.–

មន្ទីរផែនការរាជធានី ខេត្ត មានការិយាល័យជំនាញចំណុះចំនួន០៨(ប្រាំបី)ដូចខាងក្រោម៖

១. ការិយាល័យរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
២. ការិយាល័យផែនការ
៣. ការិយាល័យស្ថិតិ
៤. ការិយាល័យតាមដានត្រួតពិនិត្យ និងវាយតម្លៃ
៥. ការិយាល័យប្រជាជន និងអភិវឌ្ឍន៍
៦. ការិយាល័យស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៧. ការិយាល័យគ្រប់គ្រងទិន្នន័យ បច្ចេកវិទ្យា និងព័ត៌មាន
៨. ការិយាល័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

Adobe Acrobat Document

# ២.លទ្ធផលការងារ សម្រេចបានក្នុងឆ្នាំ២០២៣

# ២.១.លទ្ធផលការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

- បានថែរក្សាសំណុំឯកសារ ការតាក់តែងលិខិត រដ្ឋបាល និងការចរាចរលិខិតរដ្ឋបាល
- បានរៀបចំផែនការ និងរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ថ្នាក់ដឹកនាំ មន្ត្រីរាជការបានចូលរួមគ្រប់សកម្មភាពសង្គមនានារបស់រាជធានី ខេត្ត សិក្ខាសាលា វេទិកាសាធារណៈ កិច្ចប្រជុំទាំងនៅក្នុង និងក្រៅខេត្ត បានរក្សាសន្តិសុខ និងរក្សាអនាម័យ សោភ័ណ្ឌភាពមន្ទីរផែនការរាជធានី ខេត្ត

- បានគ្រប់គ្រងស្ថានភាពមន្ត្រីរាជការ វត្តមានមន្ត្រីរាជការ រៀបចំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល ការស្នើសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិ សំណើរសុំគ្រឿងឥស្សរិយយសរបស់មន្ត្រីរាជការ
- បានរៀបចំឯកសារសំណើរសុំមន្ត្រីកិច្ចសន្យាមន្ទីរផែនការឆ្នាំ២០២៣
- បានដំណើរការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការឆ្នាំ២០២៣

- បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា រៀបចំផែនការថវិកាប្រចាំឆ្នាំ ផែនការលទ្ធកម្មប្រចាំឆ្នាំ និងបានអនុវត្តការចំណាយហិរញ្ញវត្ថុសាធារណៈ អនុវត្តនិតិវិធីលទ្ធកម្មសាធារណៈសម្រាប់ឆ្នាំ២០២៣
- បានគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរដ្ឋ និងបិទផ្លាកលេខកូដសំគាល់សម្ភារៈ រៀបចំបញ្ជីសារពើភ័ណ្ឌសម្រាប់ឆ្នាំ២០២៣ ឆ្នាំគោល២០២២ និងគ្រប់គ្រងការប្រើប្រាស់ប្រេងឥន្ធនៈ និងសម្ភារៈការិយាល័យ។

# ២.២.លទ្ធផលការងារផែនការ

## ២.២.១.ប្រវត្តិសង្ខេបផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគឃុំ/សង្កាត់

### ឆ្នាំ ២០០១

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ




### ឆ្នាំ ២០០២

- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ (២០០២-២០០៧)




### ពីឆ្នាំ ២០០២ រហូតបច្ចុប្បន្ន

- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់

✓ នីតិវិធីការងារ រដ្ឋបាល

✓ ប្រព័ន្ធផែនការ

**ប្រព័ន្ធផែនការឃុំ/សង្កាត់**

✓ ការបង្កើតមូលនិធិឃុំ សង្កាត់

✓ ប្រព័ន្ធហិរញ្ញវត្ថុ

**ដំណាក់កាលធំៗ ការបច្ចុប្បន្នភាពសេចក្តីណែនាំបច្ចេកទេសរៀបចំផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគឃុំ សង្កាត់**

**ដំណាក់កាលទី១ (២០០២-២០០៧)**

**ដំណាក់កាលទី២ (២០០៧-២០១៧)**

**ដំណាក់កាលទី៣ ពីឆ្នាំ ២០១៧ ដល់បច្ចុប្បន្ន**

# ២.២.លទ្ធផលការងារផែនការ(ត)

## ២.២.២.ប្រវត្តិសង្ខេបផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ឆ្នាំ ២០០៨**

- វិសោធនកម្មរដ្ឋធម្មនុញ្ញ
- ច្បាប់រៀបចំអង្គការ



រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

ច្បាប់
ស្តីពី
ការគ្រប់គ្រងរដ្ឋបាល
រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

Law on
Administrative Management of the Capital,
Provinces, Municipalities, Districts and Khans

ច្បាប់
ស្តីពី
ការបោះឆ្នោតជ្រើសរើស
ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង
ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

Law on
The Election of Capital Council, Provincial Councils,
Municipal Councils, District Councils
and Khan Councils

ការផ្សាយរបស់ក្រសួងមហាផ្ទៃ
បោះពុម្ពឡើងវិញ ចំនួន ៣០.០០០ក្បាល ខែវិច្ឆិកា ឆ្នាំ២០០៩
Published by the Ministry of Interior
Reprint, 30,000 copies, November 2009

**ឆ្នាំ ២០០៩**

- ការបោះឆ្នោតក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងទើបវិញ



- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៃរាជធានី ខេត្ត ក្រុង/ស្រុក ខណ្ឌ

✓ ប្រព័ន្ធផែនការ

**ប្រព័ន្ធផែនការ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ដំណាក់កាលធំៗ ការបច្ចុប្បន្នភាពសេចក្តីណែនាំបច្ចេកទេសរៀបចំផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

↓

**ដំណាក់កាលទី១ (២០១០-២០១៣)**

↓

**ដំណាក់កាលទី២ (២០១៣-២០១៧)**

↓

**ដំណាក់កាលទី៣ ពីឆ្នាំ ២០១៧ ដល់បច្ចុប្បន្ន**

# ២.២.លទ្ធផលការងារផែនការ(ត)

## ២.២.៣.លទ្ធផលការងាររៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ/សង្កាត់




១.សម្របសម្រួលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

២.សម្របសម្រួលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង/ស្រុក/ខណ្ឌ

៣.សម្របសម្រួលរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ/សង្កាត់

# ២.២.លទ្ធផលការងារផែនការ(ត)

**មន្ទីរផែនការខេត្ត និងជាសមាជិកអចិន្ត្រៃយ៍ក្រុមការងារកសាងផែនការខេត្ត**

- ➢ បានសហការរៀបចំវគ្គបណ្តុះបណ្តាលការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធិវិនិយោគបីឆ្នាំរំកិល
- ➢ រៀបចំឯកសារគោលការណ៍ណែនាំផ្នែកគោលនយោបាយ សេចក្តីណែនាំ ប្រតិទិនសម្រាប់រៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(២០២៥-២០២៩) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦)រាជធានី ខេត្ត
- ➢ បានសម្របសម្រួល កិច្ចប្រជុំ សិក្ខាសាលាសមាហរណកម្មផែនការ និងវេទិការពីគ្រោះយោបល់កម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦)រាជធានី ខេត្ត
- ➢ រៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦)រាជធានី ខេត្ត ជូនគណៈអភិបាលរាជធានី ខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសពិនិត្យ ផ្តល់យោបល់ និងជូនក្រុមប្រឹក្សាពិនិត្យ អនុម័ត
- ➢ សម្របសម្រួលរៀបចំបោះពុម្ពកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦)រាជធានី ខេត្ត ផ្សព្វផ្សាយប្រើប្រាស់






# ២.២.លទ្ធផលការងារផែនការ(ត)

## ២.២.៤.ការងារទិន្នន័យមូលដ្ឋាន

ទិន្នន័យមូលដ្ឋានឃុំសង្កាត់មកដល់បច្ចុប្បន្ន បានឆ្លងកាត់ការកែសំរួល៥ដំណាក់កាល គឺ ៖













1998-2001
រៀបចំបង្កើតនិង
សាកល្បង

2002-2005
គ្រប់ភូមិនិងឃុំសង្កាត់
ភូមិ៨៩ ឃ/ស ១៩

2006
កែសម្រួលភូមិនិងឃ/ស
ភូមិ៣២០ ឃ/ស ២១៧

2011
ភូមិ៦៤៧
ឃ/ស ២៤៥ ក/ស/
ខ១៩១

2019
ភូមិ៦៨៧
ឃ/ស ២៤៥
ក/ស/ខ១៧៧

# ២.២.លទ្ធផលការងារផែនការ(ត)

## ២.២.៤.ការងារទិន្នន័យមូលដ្ឋាន

**ទិសដៅទិន្នន័យមូលដ្ឋាន**

- រៀបចំឯកសារព័ត៌មានស្ថានភាពឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងរាជធានី ខេត្ត។
- រៀបចំឯកសារពិន្ទុវិស័យឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងរាជធានី ខេត្ត។
- **វិភាជន៍ធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ**
- វិភាគស្ថានភាពដើម្បីកំណត់ សកម្មភាពជាអាទិភាព កំណត់គោលដៅអភិវឌ្ឍន៍ សម្រាប់រៀបចំផែនការ និងកម្មវិធីវិនិយោគ
- ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវឌ្ឍនភាព

### ឃុំ សង្កាត់

- **សេវាសង្គម អនាម័យបរិស្ថាន**
  ៣០%_ចំណែកស្មើគ្នា
  ២០%_ចំនួនប្រជាពលរដ្ឋ
  ៥០%_សន្ទស្សន៍ភាពក្រីក្រ
- **អភិវឌ្ឍន៍មូលដ្ឋាន**
  ៣០%_ចំណែកស្មើគ្នា
  ៣០%_ចំនួនប្រជាពលរដ្ឋ
  ៣០%_សន្ទស្សន៍ភាពក្រីក្រ
  ១០%_សមាមាត្រចំនួនភូមិ

*(អនុក្រិត្យលេខ១៥៣)*



### ក្រុង ស្រុក

- **សេវាសង្គម អនាម័យបរិស្ថាន**
  ៣០%_ចំណែកស្មើគ្នា
  ២០%_ចំនួនប្រជាពលរដ្ឋ
  ៥០%_សន្ទស្សន៍ភាពក្រីក្រ
- **អភិវឌ្ឍន៍មូលដ្ឋាន**
  ៤០%_ចំណែកស្មើគ្នា
  ២០%_ចំនួនប្រជាពលរដ្ឋ
  ៤០%_សន្ទស្សន៍ភាពក្រីក្រ

*(អនុក្រិត្យលេខ១៥២)*



# ២.២.លទ្ធផលការងារផែនការ(ត)

## ផលិតផលទិន្នន័យមូលដ្ឋាន CDB ក្នុងការគាំទ្រផែនការថ្នាក់ក្រោមជាតិ



- វឌ្ឍនភាពការកាត់បន្ថយភាពក្រីក្រនៅថ្នាក់ក្រោមជាតិ(Poverty-CDB)
- ធ្វើការបែងចែកមូលនិធិឃុំសង្កាត់និងក្រុងស្រុក
- ឯកសារព័ត៌មានស្ថានភាពខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់
- វឌ្ឍនភាពការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅថ្នាក់ក្រោមជាតិ(CMDG-CDB)
- តារាងពិន្ទុតាមបណ្តាវិស័យ ខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ ឃុំសង្កាត់

# ២.២.លទ្ធផលការងារផែនការ(ត)

## ដំណើរការការងារទិន្នន័យមូលដ្ឋាននៅថ្នាក់រាជធានី ខេត្ត

**ការងារទិន្នន័យមូលដ្ឋាន (CDB)**

1. បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្ត
2. បណ្តុះបណ្តាលការប្រមូលទិន្នន័យ ដល់មេឃុំ ស្មៀន មេភូមិ អនុភូមិ
3. ដំណើរការប្រមូលទិន្នន័យភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ
4. ការបញ្ចូលទិន្នន័យភូមិ ឃុំ ក្រុង/ស្រុក ក្នុងកម្មវិធីCDB Program
5. ការផលិតឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យ
6. សិក្ខាសាលាស្តីពីការផ្សព្វផ្សាយ ប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព និងពិន្ទុវិស័យ

# ២.២.លទ្ធផលការងារផែនការ(ត)

**ការងារបណ្តុះបណ្តាលទិន្នន័យមូលដ្ឋាន៖**

ឆ្នាំ២០២៣មន្ទីរផែនការរាជធានី ខេត្ត បាន៖

- បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់រាជធានី ខេត្ត ស្តីពីការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្រុង/ស្រុក
- បើកវគ្គបណ្តុះបណ្តាលស្តីពីការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្រុង/ស្រុក ដល់មេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ និងប្រធានភូមិ នៅថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ ។
- បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីការស្តីពីការបញ្ចូលទិន្នន័យមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្រុង/ស្រុក និងការផលិតឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវស័យរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។

**ដំណើរការប្រមូលទិន្នន័យមូលដ្ឋាន**

នៅដើមខែធ្នូ ឆ្នាំ២០២៣ មន្ត្រីរាជការមន្ទីរផែនការរាជធានី ខេត្ត បានចុះតាមឃុំ សង្កាត់សម្របសម្រួលដំណើរប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ នៅគ្រប់ភូមិ ក្រុង/ស្រុក/ខណ្ឌ នៃរាជធានី ខេត្ត



# ២.២.លទ្ធផលការងារផែនការ(ត)

**ការពិនិត្យផ្ទៀងផ្ទាត់ និងការបញ្ចូលទិន្នន័យ**

នៅចុងខែធ្នូ ឆ្នាំ២០២៣ មន្ទីរផែនការរាជធានី ខេត្ត បានដំណើរការប្រមូល ការពិនិត្យផ្ទៀងផ្ទាត់ ការបញ្ចូលទិន្នន័យមូលដ្ឋានទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ កម្មវិធី CDB7 Program ដែលត្រូវបញ្ចូលគ្រប់ភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌនៃរាជធានី ខេត្តនីមួយៗ



**ដំណើរការផលិតឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវស័យ**

នៅចុងខែធ្នូ ឆ្នាំ២០២៣ និងខែមករា ឆ្នាំ២០២៤ មន្ត្រីរាជការមន្ទីរផែនការរាជធានី ខេត្ត បានដំណើរការ៖

- ផលិតឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់
- ផលិតឯកសារព័ត៌មានពិន្ទុវិស័យរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់
- ផ្ញើ Access File ទិន្នន័យមូលដ្ឋាន មកក្រសួងផែនការ





# ២.២.លទ្ធផលការងារផែនការ (ត)



**ការផ្សព្វផ្សាយការប្រើប្រាស់ទិន្នន័យមូលដ្ឋាន**

- នៅខែកុម្ភៈ ឆ្នាំ២០២៣ មន្ទីរផែនការរាជធានី ខេត្តបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ជាឧបករណ៍ទិន្នន័យ និងការវិភាគសម្រាប់រៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលថ្នាក់ក្រោមជាតិ។
- មន្ទីរអង្គភាព និងស្ថាប័នឯកសារព័ត៌មានស្ថានភាពរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ដល់ស្ថាប័នពាក់ព័ន្ធយកទៅប្រើប្រាស់ក្នុងគោលបំណងអភិវឌ្ឍន៍៖
  - **មន្ទីរអប់រំ យុវជននិងកីឡា**៖រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨រៀបចំផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍន៍ការអប់រំក្រៅប្រព័ន្ធ
  - **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំរបស់មន្ទីរ និងផែនការសកម្មភាពក្នុងការគ្រប់គ្រងទិន្នន័យជនមានពិការភាព
  - **មន្ទីរដែនដី នគរូបនីយកម្ម និងសំណង់** ប្រើប្រាស់ក្នុងការគ្រប់គ្រង និងបែងចែកដីសម្បទានសេដ្ឋកិច្ច សង្គមកិច្ច
  - **មន្ទីរអភិវឌ្ឍន៍ជនបទ** ប្រើប្រាស់ក្នុងការគ្រប់គ្រងការប្រើប្រាស់ទឹកស្អាត និងអនាម័យ រៀបចំផែនការផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ

# ២.២.លទ្ធផលការងារផែនការ(ត)



## ការផ្សព្វផ្សាយការប្រើប្រាស់ទិន្នន័យមូលដ្ឋាន

- **មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ប្រើប្រាស់ក្នុងការវិភាគអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចខេត្ត ដាក់បញ្ចូលទៅក្នុងគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- **គណៈកម្មាធិការគ្រប់គ្រងគ្រោះមន្តរាយខេត្ត** ប្រើប្រាស់ក្នុងការរៀបចំផែនការគ្រប់គ្រង ការឆ្លើយតប និងការត្រៀមបង្ការ ពេលមានគ្រោះហន្តរាយកើតឡើងក្នុងខេត្ត
- **អង្គការលំនៅឋាន អន្តរជាតិកម្ពុជា** (HFHC) សិក្សាប្រមូលទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តគម្រោងស្រាវជ្រាវស្តីពីទិដ្ឋភាពទូទៅលំនៅឋានសម្រាប់គ្រួសារដែលមានចំណូលទាបនៅក្នុងប្រទេសកម្ពុជា និងវាស់វែងនូវលក្ខខណ្ឌទូទៅនៃលំនៅឋាន កំណត់ទិដ្ឋភាពនៃវិស័យលំនៅឋាន និងការវិភាគស៊ីជម្រៅ ។
- **ធនាគារអេស៊ីលីដា** ស្ថិតិគ្រួសារ និងចំនួនប្រជាពលរដ្ឋតាមភូមិ និងឃុំសង្កាត់
- **និស្សិតមកពីវិទ្យាស្ថាន និងសកលវិទ្យាល័យ** ដើម្បីសិក្សាស្រាវជ្រាវ ក្នុងការសសេររបាយការណ៍ និងការសរសេរនិក្ខេបបទ បញ្ចប់ការសិក្សា
- អង្គការ និងស្ថាប័នមួយចំនួនទៀត ដែលបានទំនាក់ទំនងប្រើប្រាស់ទិន្នន័យ និងឯកសារព័ត៌មានស្ថានភាព សម្រាប់គោលបំណងសិក្សា និងរៀបចំផែនការអភិវឌ្ឍន៍នានា។

# ២.៣.លទ្ធផលការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ

## ២.៣ .១.ការងារគ្រប់គ្រងទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ (SPD )

- បញ្ចូលគម្រោងអាទិភាពរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ក្នុងកម្មវិធីគ្រប់គ្រង SPD .
- បានរៀបចំ ផលិតតារាងម៉ាទ្រិចសកម្មភាពជាអាទិភាពក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់
- តាមដាន បច្ចុប្បន្នភាពវឌ្ឍនភាពនៃការអនុវត្តគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង/ស្រុក និងឃុំ/សង្កាត់នៅក្នុងកម្មវិធីគ្រប់គ្រងទិន្នន័យគម្រោងថ្នាក់ក្រោមជាតិប្រចាំត្រីមាសនៃឆ្នាំ២០២៣



CDPD 2.2.exe

CDPD 3.exe

Commune Development Planning Database




Sub-National Project Database

# ២.៣.លទ្ធផលការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ(ត)

## ២.៣.២.ការតាមដានការអនុវត្តគម្រោងកម្មវិធីវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

- **កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្តៈ** បានរៀបចំកិច្ចប្រជុំតាមដាន ត្រួតពិនិត្យ និង រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥) រាជធានី ខេត្ត និងបោះពុម្ពផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ
- **កម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង/ស្រុក/ខណ្ឌៈ** បានចុះតាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍អនុវត្តគម្រោង សកម្មភាពកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង/ស្រុក (គម្រោងប្រើប្រាស់មូលនិធិក្រុង/ស្រុក  គម្រោងសន្យាគាំទ្រ ....)ប្រចាំត្រីមាសនៃឆ្នាំ២០២៣
- **កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ/សង្កាត់ៈ** ចុះតាមដានត្រួតពិនិត្យ និងរៀបចំរបាយការណ៍ការអនុវត្តគម្រោង សកម្មភាពកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ/សង្កាត់ (គម្រោងប្រើប្រាស់មូលនិធិឃុំ សង្កាត់  គម្រោងសន្យាគាំទ្រដែលបានចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន ....) ប្រចាំត្រីមាស នៃឆ្នាំ២០២៣



# ២.៣.លទ្ធផលការខារតាមដានត្រួតពិនិត្យ និងវាយតម្លៃ(ត)

## ២.៣.៣. ការខារតាមដានការអនុវត្តនិតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

**វាយតម្លៃវឌ្ឍនភាព:** តើសកម្មភាពត្រូវបានអនុវត្តតាមផែនការ ? តើគោលដៅត្រូវបានសម្រេច ?

**ការធានាគុណភាព:** តើការអនុវត្តសកម្មភាពតាមស្តង់ដារ គុណភាពរំពឹងទុក ?

**ការរកឃើញបញ្ហាទាន់ពេលវេលា** តើមានបញ្ហាអ្វីខ្លះដែលត្រូវដោះស្រាយ ?

**ការរៀនសូត្រ និងការកែលម្អ** តើអ្វីជាមេរៀនដែលបានពីការអនុវត្ត ? តើយើងត្រូវកែសម្រួលយុទ្ធសាស្ត្ររបស់យើងទេ ?

**ការគ្រប់គ្រងធនធាន** តើមានធនធានគ្រប់គ្រាន់ ? តើធនធានត្រូវបានប្រើប្រាស់ទៅតាមគោលបំណង ?

**ការវាយតម្លៃ និងរបាយការណ៍** តើនីតិវិធី បានអនុវត្តត្រឹមត្រូវ ? តើលទ្ធផលបង្ហាញថានីតិវិធីមានប្រសិទ្ធភាព ?



- គ្រួសារទី៥ ឈ្មោះ ប៊ិម សម្បត្តិ
- មានបណ្ណសមធម៌ ក្រកម្រិត២
- លទ្ធផលសម្ភាសន៍ របស់ក្រុមការងារបច្ចេកទេស ចេញស្ថានភាព ក្រកម្រិត២



- ភូមិកោះតាម៉ូវ ឃុំកំពង់ព្រះគគីរ ស្រុកបរិបូណ៌

- គ្រួសារទី១ ឈ្មោះ ជុំ ភា
- គ្រួសារពុំមានបណ្ណ
- លទ្ធផលសម្ភាសន៍ របស់ក្រុមការងារបច្ចេកទេស ចេញស្ថានភាព ក្រកម្រិត២



- គ្រួសារទី៥ ឈ្មោះ ភួង សុគន្ធា
- មានបណ្ណសមធម៌ ក្រកម្រិត២
- លទ្ធផលសម្ភាសន៍ របស់ក្រុមការងារបច្ចេកទេស ចេញស្ថានភាព ក្រកម្រិត២



# ២.៤.លទ្ធផលការងារស្ថិតិ (ត)

## ២.៤.១.លទ្ធផលការងារស្ថិតិរដ្ឋបាលប្រជាសាស្ត្រ និងវិស័យសេដ្ឋកិច្ច សង្គមកិច្ច

- បានសម្របសម្រួលដំណើរការប្រមូលស្ថិតិរដ្ឋបាលប្រជាសាស្ត្រប្រចាំត្រីមាស ឆ្នាំ ២០២៣ និងបូកសរុបចងក្រងរបាយការណ៍រដ្ឋបាលស្ថិតិប្រជាសាស្ត្រនិងបោះពុម្ពផ្សព្វផ្សាយ។
- បានសម្របសម្រួលប្រមូលទិន្នន័យស្ថិតិរដ្ឋបាលវិស័យសេដ្ឋកិច្ច សង្គមកិច្ច៖
  - វិស័យសេដ្ឋកិច្ច៖មានស្ថិតិវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម រ៉ែនិងឋាមពល សណ្ឋាគារ ផ្ទះសំណាក់ ពាណិជ្ជកម្ម(ផ្សារនិងតូបអាជីវកម្ម).......
  - ស្ថិតិផ្នែកសង្គមកិច្ច មានស្ថិតិវិស័យអប់រំមានស្ថិតិសាលារៀនគ្រប់កម្រិតទាំងពីបឋមសិក្សា រហូតមហាវិទ្យាល័យ ស្ថិតិវិស័យសុខាភិបាលមានស្ថិតិមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព ស្ថិតិវិស័យសាសនាពីចំនួនវត្តអារាមព្រះពុទ្ធសាសនា គ្រឹះសាសនា និងឥស្លាមសាសនា ....។



# ២.៤.លទ្ធផលការងារស្ថិតិ (ត)

## ២.៤.២.ការងារតម្លៃទំនិញទីផ្សារ និងប្រមូលទិន្នន័យផលិតផលក្នុងស្រុកសរុប

- បានចុះស្រង់តម្លៃទំនិញទីផ្សារប្រចាំខែ លើមុខទំនិញចំនួន២៥៥មុខ និង បូកសរុបផ្ញើជូននាយកដ្ឋានគណនេយ្យជាតិក្រសួងផែនការជារៀងរាល់ខែ
- បានរៀបចំកិច្ចប្រជុំប្រមូលទិន្នន័យ និងដំណើរការប្រមូលទិន្នន័យវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យសេវាកម្ម សម្រាប់គណនាផលិតផលក្នុងស្រុកសរុបជូននាយកដ្ឋានគណនេយ្យជាតិក្រសួងផែនការ
- បានបោះពុម្ពព្រឹត្តិបត្រផលិតផលក្នុងស្រុកសរុបរបស់ខេត្ត និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយផលិតផលក្នុងស្រុកសរុបរបស់ខេត្តកំពង់ឆ្នាំង








# ២.៤.លទ្ធផលការងារស្ថិតិ (ត)

## ២.៤.៣.លទ្ធផលការងារធ្វើជំរឿន និងធ្វើអង្កេតនានា

**ការងារជំរឿន៖** ជំរឿនកសិកម្មព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣

- បានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ បើកវគ្គបណ្តុះបណ្តាលជំរឿនកសិកម្មដល់មន្ត្រីត្រួតពិនិត្យ មន្ត្រីសម្ភាស ជំរឿនកសិកម្មនៅថ្នាក់រាជធានី ខេត្ត។
- មន្ត្រីមន្ទីរផែនការរាជធានី ខេត្ត បានចូលរួម និងចុះប្រតិបត្តិការស្រង់ទិន្នន័យជំរឿនកសិកម្មព្រះរាជាណាចក្រកម្ពុជា។

**ការងារអង្កេត៖**

➢ **អង្កេតសេដ្ឋកិច្ច សង្គមកិច្ច៖** មន្ត្រីរាជការមន្ទីរផែនការរាជធានី ខេត្ត បានចូលរួមធ្វើអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០២៣នៅតាមបណ្តាខេត្ត។

➢ **អង្កេតកសិកម្ម៖**មន្ត្រីរាជការមន្ទីរផែនការរាជធានី ខេត្ត ចូលរួមធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ នៅតាមបណ្តាខេត្ត។



# ២.៥.លទ្ធផលការងារប្រជាជន និងអភិវឌ្ឍន៍

## ២.៥.១.លទ្ធផលការងារបណ្តុះបណ្តាល ផ្សព្វផ្សាយគោលនយោបាយជាតិប្រជាជន

- បានចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការសកម្មភាពផ្សារភ្ជាប់នឹងគោលនយោបាយរវាងអគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ និងមន្ទីរផែនការ រាជធានី ខេត្ត និងចូលរួមសិក្ខាសាលាស្តីពីការជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(កត្តាប្រជាជន និងអភិឌ្ឍន៍)
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីគោលនយោបាយជាតិប្រជាជននិងប្រជាសាស្រ្តម៉ូឌុល១(វគ្គ២)
- បានរៀបចំសិក្ខាសាលាស្តីពីការវិភាគបញ្ហាប្រឈម និងកាលានុវត្តភាពនៃការធ្វើទេសន្តរប្រវេសន៍ និងស្តីពីមនុស្សវ័យចាស់ក្នុងក្របខណ្ឌគោលនយោបាយជាតិប្រជាជននៅថ្នាក់ក្រុង ស្រុក ។

## ២.៥.២.លទ្ធផលការងារចងក្រងទិន្នន័យសហគមន៍

- បានរៀបចំកិច្ចប្រជុំជាមួយមន្ទីរអង្គភាពជុំវិញខេត្តស្តីពីការប្រមូលទិន្នន័យសហគមន៍ និងសម្របសម្រួលដំណើរការប្រមូលទិន្នន័យសហគមន៍ពីមន្ទីរអង្គភាព និងតាម បណ្តាក្រុង ស្រុក
- បានរៀបចំរបាយការណ៍ស្តីពីទិន្នន័យសហគមបញ្ជូនមកអគ្គលេខាធិការប្រជាជននិងការអភិវឌ្ឍន៍ និងបោះពុម្ពផ្សព្វផ្សាយប្រើប្រាស់។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកំពង់ឆ្នាំង

របាយការណ៍

ស្តីពីទិន្នន័យសហគមន៍ឆ្នាំ២០២២



រៀបចំដោយ៖ ការិយាល័យប្រជាជន និងការអភិវឌ្ឍ នៃមន្ទីរផែនការខេត្តកំពង់ឆ្នាំង
ខែ...............ឆ្នាំ២០២២

# ២.៥.លទ្ធផលការងារប្រជាជន និងអភិវឌ្ឍន៍(ត)

## ២.៥.៣.លទ្ធផលការងារសិក្សាស្រាវជ្រាវ ពាក់ព័ន្ធគោលនយោបាយជាតិប្រជាជន

- បានសិក្សានិងរៀបចំរបាយការណ៍ស្តីពីស្ថានភាពបម្រែបម្រួលប្រជាជនក្នុងក្របខណ្ឌគោលនយោបាយជាតិប្រជាជនឆ្នាំ២០១៦-២០៣០ និងបោះពុម្ពផ្សព្វផ្សាយដល់អ្នកប្រើប្រាស់
- បានសិក្សា រៀបចំចងក្រងរបាយការណ៍វិភាគស្តីពីភាគលាភប្រជាសាស្ត្រនិងបោះពុម្ពផ្សព្វផ្សាយប្រើប្រាស់ ។

ការសិក្សា និងរៀបចំរបាយការណ៍ទទួលបានការបណ្តុះបណ្តាលផ្នែកបច្ចេកទេស ការប្រមូលទិន្នន័យ ការស្រាវជ្រាវ ការវិភាគសូចនាករប្រជាសាស្ត្រ និងគំរូរបាយការណ៍ពីអគ្គលេខាធិការប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការ



# ២.៦.លទ្ធផលការងារគ្រប់គ្រងទិន្នន័យ បច្ចេកវិទ្យា និងព័ត៌មាន

- មន្ទីរផែនការរាជធានី ខេត្ត បានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិបើកវគ្គបណ្តុះបណ្តាលស្តីពីការកែដៃ ដាក់កូដ និងបញ្ចូលទិន្នន័យជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ និងជំរឿនកសិកម្មឆ្នាំ២០២៣
- បានដំណើរការកែដៃ ដាក់កូដ និងបញ្ចូលទិន្នន័យជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ និងជំរឿនកសិកម្មឆ្នាំ២០២៣គឺបានចូលរួមកែដៃ ដាក់កូដទម្រង់៣ ទម្រង់៤ និងបញ្ចូលទិន្នន័យទម្រង់១ ទម្រង់២ ទម្រង់៣ ទម្រង់៤ នៃជំរឿនកសិកម្មព្រះរាជាណាចក្រកម្ពុជានៅតាមរាជធានី ខេត្តរបស់ខ្លួន
- បានគ្រប់គ្រង និងបញ្ជូនទិន្នន័យដែលបានបញ្ចូលរួច ទៅវិទ្យាស្ថានជាតិស្ថិតិ
- បានផ្សព្វផ្សាយព័ត៌មានសកម្មភាពការងាររបស់មន្ទីរផែនការ នៅក្នុង Page Facebook មន្ទីរផែនការរាជធានី ខេត្ត។

# ២.៧.លទ្ធផលការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ត)

## ២.៧.១.ការងារសម្របសម្រួលកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ

- ➢ បានបើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលថ្នាក់ខេត្តស្ដីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងបើកវគ្គបណ្ដុះបណ្ដាលថ្នាក់ក្រុង/ស្រុកស្ដីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់ក្រុមមេឃុំ ចៅសង្កាត់ និងក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រឃុំ សង្កាត់។
- ➢ បានចុះសម្របសម្រួលដំណើរការនៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតាមភូមិ ឃុំ/សង្កាត់ឲ្យអនុវត្តស្របតាមសេចក្ដីណែនាំ៖

**មុខងារទាំងប្រាំ នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**

- ➢ កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- ➢ ធ្វើបច្ចុប្បន្នកម្មទិន្នន័យដោយកែសម្រួលព័ត៌មានគ្រួសារ
- ➢ ធ្វើបច្ចុប្បន្នកម្មទិន្នន័យដោយដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រ
- ➢ មុខងារតាមដានត្រួតពិនិត្យ
- ➢ យន្តការគ្រប់គ្រងមតិជំទាស់ និងសំណូមពរ

# ២.៧.លទ្ធផលការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ត)

## ២.៧.២.ការងារសម្របសម្រួលដោះស្រាយសំណូមពរ មតិជំទាស់

- មន្ត្រីបានចុះសម្របសម្រួលដោះស្រាយសំណូមពរមតិជំទាស់នៅតាមឃុំ សង្កាត់ និងតាមកម្មវិធី App IDPoor
- ផ្សព្វផ្សាយពីការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រដល់ប្រជាជនទូទៅ







## ២.៧.៣.ការងារសម្របសម្រួលបោះពុម្ព និងចែកប័ណ្ណសមធម៌

- បានចុះសម្របសម្រួលចែកប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋតាមភូមិ ឃុំ សង្កាត់ និងបោះពុម្ពប័ណ្ណសមធម៌ ប័ណ្ណគ្រួសារងាយរងហានិភ័យជូនប្រជាពលរដ្ឋដែលបាត់។









# ៣.បញ្ហាប្រឈម និងសំណូមពរ

# ៣.១.បញ្ហាប្រឈម

- មន្ទីរផែនការរាជធានីខេត្ត មានការិយាល័យជំនាញចំនួន៨ មានការិយាល័យចំនួន៦ ទទួលបានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ការិយាល័យចំនួន២គឺ (១)ការិយាល័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និង(២)ការិយាល័យគ្រប់គ្រងទិន្នន័យ បច្ចេកវិទ្យានិងព័ត៌មាន ពុំទទួលបានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ទោះបីមានខេត្តខ្លះបានតែងតាំងរៀបចំរចនាសម្ព័ន្ធរួចហើយតែពុំអាចបញ្ចូលក្នុងតារាងបៀវត្សបាននៅឡើយ។
- សមត្ថភាពមន្ត្រីរាជការនៅមន្ទីរផែនការរាជធានី ខេត្តនៅមានកម្រិត ពិសេសការបច្ចុប្បន្នភាពទិន្នន័យCDB7 លើការងារបន្ថែមភូមិ ឃុំ សង្កាត់បង្កើតថ្មី និងទិន្នន័យដែលមានបញ្ហាលើការធ្វើបច្ចុប្បន្នភាពនៃបច្ចេកវិទ្យា។
- ពុំទាន់មានសេចក្តីណែនាំបច្ចេកទេសស្តីពីតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ខេត្ត ក្រុង/ស្រុក និឃុំ សង្កាត់ និងសេចក្តីណែនាំរៀបចំរបាយការណ៍វឌ្ឍភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង/ស្រុក
- សមត្ថភាពមន្ត្រីនៅតាមមន្ទីរផែនការរាជធានី ខេត្តនៅមានកម្រិត លើការងារវិភាគ ស្រាវជ្រាវចងក្រងឯកសារស្ថិតិពិសេសស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ការគណនាផលិតផលក្នុងស្រុកសរុបរបស់រាជធានី ខេត្ត និងការវិភាគទិន្នន័យ ការសរសេររបាយការណ៍ស្រាវជ្រាវស្តីពីប្រជាជន និងអភិវឌ្ឍន៍ស្របតាមស្ថានភាពប្រជាសាស្ត្រនៃរាជធានី ខេត្តក្នុងក្របខណ្ឌនៃការអនុវត្តគោលនយោបាយជាតិនិងប្រជាជន។

# ៣.២.សំណូមពរ

សូមគោរពស្នើសុំ

- សុំទិដ្ឋាការពីក្រសួងមុខងារសាធារណៈការិយាល័យចំនួន២គឺ(១)ការិយាល័យអត្តសញ្ញាណកម្មគ្រូសារក្រីក្រ និង(២) ការិយាល័យគ្រប់គ្រងទិន្នន័យ បច្ចេកវិទ្យានិងព័ត៌មាន នៃរចនាសម្ព័ន្ធមន្ទីរផែនការរាជធានី ខេត្ត
- បណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីរាជការនៅមន្ទីរផែនការរាជធានី ខេត្ត លើប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋាន CDB7 និងមានមន្ត្រីបច្ចេកវិទ្យាIT នៃក្រសួងផែនការជួយដោះស្រាយបញ្ហាប្រព័ន្ធគ្រប់គ្រងទិន្នន័យបានទាន់ពេល។
- សូមរៀបចំសេចក្ដីណែនាំបច្ចេកទេសស្ដីពីតាមដានការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង/ស្រុក និង ឃុំ សង្កាត់ និងសេចក្ដីណែនាំរៀបចំរបាយការណ៍វឌ្ឍភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង/ស្រុក
- បណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ទីរផែនការរាជធានី ខេត្ត បន្ថែមទៀត លើការងារវិភាគ ចងក្រងឯកសារស្ថិតិ ការងារស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ការគណនាផលិតផលក្នុងស្រុកសរុបរបស់រាជធានី ខេត្ត និង ការងារវិភាគ ចងក្រងរបាយការណ៍សិក្សាស្រាវជ្រាវស្ដីពីប្រជាជននិងការអភិវឌ្ឍ ក្នុងក្របខណ្ឌនៃការអនុវត្តគោលនយោបាយជាតិ និងប្រជាជន ។

# ៤.ផែនការសកម្មភាពការងារសំខាន់ៗ ឆ្នាំ២០២៤

# ៤.ផែនការសកម្មភាពការងារសំខាន់ៗឆ្នាំ២០២៤

**១.ការងារផែនការ**

- សម្របសម្រួលដំណើរការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(២០២៤-២០២៨) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៥-២០២៧)ខេត្ត ក្រុង/ស្រុក និងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៥-២០២៧) ឃុំ/សង្កាត់
- ដំណើរការប្រមូលទិន្នន័យមូលដ្ឋានឆ្នាំ២០២៤ ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ និងផលិតឯកសារព័ត៌មានស្ថានភាព ឯកសារពិន្ទុវិស័យ។

**២.ការងារតាមដានត្រួតពិនិត្យវាយតម្លៃ**

- គ្រប់គ្រងទិន្នន័យគម្រោងថ្នាក់ក្រោមជាតិ និងការតាមដានវឌ្ឍភាពនៃការអនុវត្តគម្រោងតាមកម្មវិធី(SPD )
- តាមដាន និងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥)រាជធានី ខេត្ត និងតាមដានអនុវត្តគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង/ស្រុក ឃុំ/សង្កាត់ឆ្នាំ២០២៤
- តាមដានត្រួតពិនិត្យ ប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មនៅតាមបណ្ដាឃុំ សង្កាត់នៃរាជធានី ខេត្ត

# ៤.ផែនការសកម្មភាពការងារសំខាន់ៗឆ្នាំ២០២៤

**៣.ការងារស្ថិតិ**

- ស្រង់ទិន្នន័យរដ្ឋបាលស្តីពីស្ថិតិប្រជាសាស្ត្រ ស្ថិតិវិស័យសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០២៤
- ស្រង់តម្លៃទំនិញទីផ្សាររៀងរាល់ខែឆ្នាំ២០២៤ និងប្រមូលទិន្នន័យសម្រាប់ផលិតផលក្នុងស្រុកសរុបឆ្នាំ២០២៣
- ចូលរួមគូសផែនទី ចុះបញ្ជីគ្រួសារ និងចុះស្រង់ទិន្នន័យអង្កេតចន្លោះជំរឿនទូទៅប្រជាជនឆ្នាំ២០២៤

**៤.ការងារប្រជាជននិងអភិវឌ្ឍន៍**

- ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយស្តីពីគោលនយោបាយជាតិប្រជាជន និងរៀបចំកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល/សិក្ខាសាលានៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង/ស្រុក/ខណ្ឌ
- សម្របសម្រួលដំណើរការប្រមូលទិន្នន័យសហគមន៍ និងចងក្រងឯកសារទិន្នន័យសហគមន៍ឆ្នាំ២០២៤
- សិក្សាស្រាវជ្រាវ បញ្ហាប្រឈម និងកាលានុវត្តភាព ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយជាតិប្រជាជន និងបញ្ជ្រាបបញ្ហាប្រជាជននិងការអភិវឌ្ឍក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈគម្រោងសេវាគាំពារសង្គម។

# ៤.ផែនការសកម្មភាពការងារសំខាន់ៗឆ្នាំ២០២៤

**៥.ការងារគ្រប់គ្រងទិន្នន័យ បច្ចេកវិទ្យា និងព័ត៌មាន**

- បន្តគ្រប់គ្រងទិន្នន័យ និងបញ្ចូលទិន្នន័យជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣នៅតាមរាជធានី ខេត្ត និងត្រួតពិនិត្យបញ្ជូនទិន្នន័យមកវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ។

**៦.ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ**

- សម្របសម្រួលការអនុវត្តនីតិវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យជាប្រចាំនៅតាមបណ្ដាឃុំ សង្កាត់នៃរាជធានី ខេត្ត ជាពិសេសរាជធានី ខេត្តដែលមានប័ណ្ណសមធម៌ផុតសុពលភាព
- ចុះសម្របសម្រួលដោះស្រាយសំណូមពរ មតិជំទាស់ជូនប្រជាពលរដ្ឋជាប្រចាំនៅតាមបណ្ដាឃុំ សង្កាត់ និងតាម IDPoor App
- សម្របសម្រួលបោះពុម្ពប័ណ្ណសមធម៌ឡើងវិញចំពោះគ្រួសារប្រជាជនដែលបាត់ប័ណ្ណ និងចុះមូលដ្ឋានឃុំ សង្កាត់ចែកប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋ។

Adobe Acrobat Document

ផែនការសកម្មភាពលំអិត

# សូមអរគុណ !